ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣៣ ✻ ៥៥

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ៧៦៤ សប់ណ ធទឧ

## សេចក្តីជូនដំណឹង

## ស្តីពី ស្ថានភាពអាកាសធាតុ នៅព្រះរាជាណាចក្រកម្ពុជា

បន្ទាប់ពីបានធ្វើការតាមដានលើស្ថានភាពអាកាសធាតុ រួចមក ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជនមេត្តាជ្រាបថា : បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជា បាន និងកំពុងទទួលឥទ្ធិពលពីប្រព័ន្ធសម្ពាធទាប ដែលអូសកាត់លើភាគឦសាននៃប្រទេស និងទទួលឥទ្ធិពលពីខ្យល់មូសុងនិរតីខ្លាំង ។

យោងតាមការព្យាករ នៅថ្ងៃទី 12 ខែកញ្ញា ឆ្នាំ 2015 ខាងមុខនេះ នឹងមានព្យុះមួយកើតឡើងនៅក្នុងសមុទ្រចិនខាងត្បូង ។ ព្យុះនេះ នឹងធ្វើដំណើរឆ្ពោះទៅតំបន់ឆ្នេរភាគកណ្តាល នៃប្រទេសវៀតណាម ។

ស្ថានភាពអាកាសធាតុបែបនេះ នឹងបង្កឱ្យមានភ្លៀងធ្លាក់ច្រើនជាបន្តបន្ទាប់ ចាប់ពីថ្ងៃទី 09 ដល់ថ្ងៃទី 13 ខែកញ្ញា ឆ្នាំ 2015 នៅក្នុងក្របខ័ណ្ឌទូទាំងប្រទេស និងអាចបណ្តាលឱ្យរាជធានី-ខេត្ត មួយចំនួន ដូចជា : រាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ កណ្តាល តាកែវ កំពត ព្រះសីហនុ កំពង់ធំ និងខេត្តសៀមរាប ប្រឈមនឹងជំនន់ទឹកភ្លៀង ។

នៅលើផ្ទៃសមុទ្រមានភ្លៀង និងខ្យល់បក់បោកខ្លាំង ។ រលកសមុទ្រអាចមានកំពស់ 1,00 - 2,50 ម៉ែត្រ ។

យោងលើស្ថានភាពអាកាសធាតុ ដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន ពិសេសចំពោះបងប្អូនប្រជានេសាទសមុទ្រ និងអ្នកធ្វើដំណើរតាមសមុទ្រ សូមបង្កើនការយកចិត្តទុកដាក់ខ្ពស់ ដើម្បីចៀសវាងនូវគ្រោះថ្នាក់ផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ ។

ក្រសួងធនធានទឹក និងឧតុនិយម បាន និងកំពុងបន្តតាមដានស្ថានភាពលើអាកាសធាតុនេះជាប់ជាប្រចាំ និងធ្វើសេចក្តីជូនដំណឹងបន្ថែម ក្នុងករណីចាំបាច់ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ ២០១៥

រដ្ឋមន្ត្រី

លឹម គានហោ

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh